ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៦០៨ "ក្រ១១" ឃ១

ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ១១៨៥

ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ ៩១០

ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ ១៨១៧

ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ០៨ និង៣០នាទីព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **១១៨៥** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] **ទិស្ស** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងជួសជុលម៉ាស៊ីនត្រជាក់ ទីកន្លែងកំណើតភូមិដែកងើក ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅបន្ទប់ជួល ផ្លូវលំ ភូមិស្រះចក សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] **វាសនា "រស់"** ម្តាយឈ្មោះ **អ៊ៅ "រស់"** នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ។

-បច្ចុប្បន្នកំពុងឃុំខ្លួននៅពន្ធនាគាររាជធានីភ្នំពេញ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ **១៩៤៦ "ឃ" ដ.ឃ.ដ** ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ។

-ជាប់ចោទពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់ឧបសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វិស្ស** ។

អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង១១និង០០នាទី នៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណី លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **វិស្ស** ភេទប្រុស អុនពេលកើតហេតុវេលាម៉ោង០០និង៣០នាទី ថ្ងៃខែឆ្នាំដដែរ ឈ្មោះ ដេត ភេទ

ប្រុស អាយុប្រហែល៣០ឆ្នាំ បានទូរស័ព្ទហៅជនរងគ្រោះមិនស្គាល់ឈ្មោះ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ មក ប្រើប្រាស់គ្រឿងញៀនជុំគ្នានៅចំណុចកើតហេតុខាងលើ ។ ពេលជនរងគ្រោះមកដល់ចំណុចកើតហេតុខាងលើ ឈ្មោះ ដេត និងឈ្មោះ [redacted] វិស្ទ បាននាំជនរងគ្រោះប្រើប្រាស់គ្រឿងញៀនហើយ ឈ្មោះ ដេត បានប្រាប់ ឈ្មោះ[redacted] វិស្ទ ថាជនរងគ្រោះមានទូរស័ព្ទដៃម៉ាក IPHONE 11PRO MAX ។ ឮដូច្នេះឈ្មោះ [redacted] វិស្ទ បានធ្វើសកម្មភាពយកកាំបិតកែច្នៃ ភ្ជង់ជនរងគ្រោះគំរាមយកទូរស័ព្ទដៃបានចំនួន០២គ្រឿង មាន IPHONE 5 ពណ៌ និងម៉ាក OPPO សេរី A94 ពណ៌ខៀវ និងកាបូបដៃ បានសម្រេចរួចគេចខ្លួន ។ ក្រោយមកឈ្មោះ [redacted] វិស្ទ បានយកទូរស័ព្ទដៃនេះទៅលក់ឱ្យឈ្មោះ ម៉ុ នៅម្តុំផ្សារ៧មករា ។ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ទើប សមត្ថកិច្ចធ្វើការស្រាវជ្រាវឃាត់ខ្លួនឈ្មោះ [redacted] វិស្ទ បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូង រាជធានីភ្នំពេញ។

-**បានឃើញ** របាយការណ៍សំយោគលេខ **៧៩/២២ រ.ប.ក** ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ របស់ការិយាល័យ ព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ **៩០៧ អ.ឃ.ក** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ **១៥៥៥ អ.ឃ.ក** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ **២១៣៥ "ឃ" ជ.ដ** ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

ទាំងសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វិស្ទ** បានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង០០និង ៣០នាទី ឈ្មោះ ដេត ភេទប្រុស បានទូរស័ព្ទហៅបុរសម្នាក់មិនស្គាល់ឈ្មោះ ដើម្បីប្រើប្រាស់គ្រឿងញៀនជុំគ្នានៅផ្ទះ របស់ឈ្មោះ តោ នៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ពេលបុរសម្នាក់ នោះមកដល់ពួកខ្លួនក៏នាំគ្នាចូលផ្ទះរបស់ឈ្មោះ តោ នាំគ្នាប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ពេលនោះឈ្មោះ ដេត ក៏បាន លួចប្រាប់ខ្លួនថាបុរសម្នាក់នោះ មានទូរស័ព្ទដៃម៉ាក IPHONE 11PROMAX ។ ពេលឮដូច្នេះខ្លួនក៏បានកាន់កាំបិតកែច្នៃ ដើរមកក្រៅផ្ទះរបស់ឈ្មោះ តោ រង់ចាំបុរសម្នាក់នោះចេញមកវិញ ដើម្បីត្រៀមប្តន់យកទូរស័ព្ទពីបុរសម្នាក់នោះ ។ លុះ ម៉ោងប្រហែល០១និង០០នាទី បុរសម្នាក់នោះក៏បានដើរចេញមកខាងក្រៅ ហើយខ្លួនក៏បានធ្វើសកម្មភាពភ្ជង់យកទូរស័ព្ទ ០២គ្រឿង ម៉ាក IPHONE5 ពណ៌ស និងទូរស័ព្ទម៉ាកOPPO ពណ៌ខៀវ បានសម្រេចរួចរត់គេចខ្លួន ។ ហើយខ្លួនបានយក ទូរស័ព្ទទៅឱ្យឈ្មោះ ម៉ុ ដើម្បីលក់នៅម្តុំផ្សារ៧មករា តែឈ្មោះ ម៉ុ បានគេចខ្លួនបាត់ទៅ ។ លុះនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០២២ ខ្លួនក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ។ ពេលនេះខ្លួនដឹងបានហើយសូមតុលាការមេត្តាជួយបន្ទរបន្តយ ទោសដល់ខ្លួនផង។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] **វិស្ទ** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ បានឆ្លើយថា កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ឈ្មោះ ដេត បានទូរស័ព្ទហៅ

បុរសម្នាក់មិនស្គាល់ឈ្មោះ ដើម្បីប្រើប្រាស់គ្រឿងញៀនជុំគ្នានៅផ្ទះរបស់ឈ្មោះ គោ នៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលបុរសម្នាក់នោះមកដល់ពួកខ្លួនក៏នាំគ្នាចូលផ្ទះរបស់ឈ្មោះ គោ នាំគ្នាប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ពេលនោះឈ្មោះ ដេត ក៏បានលួចប្រាប់ខ្លួនថាបុរសម្នាក់នោះ មានទូរស័ព្ទដៃម៉ាក IPHONE 11PROMAX ពេលឮដូច្នេះខ្លួនក៏បានកាន់កាំបិតកែច្នៃ ដើរមកក្រៅផ្ទះរបស់ឈ្មោះ គោ រង់ចាំបុរសម្នាក់នោះចេញមកវិញ ដើម្បីត្រៀមប្លន់យកទូរស័ព្ទពីបុរសម្នាក់នោះ លុះម៉ោងប្រហែល ០១និង០០នាទី បុរសម្នាក់នោះក៏បានដើរចេញមកខាងក្រៅ ហើយខ្លួនក៏បានធ្វើសកម្មភាពភ្ជង់យកទូរស័ព្ទ០២គ្រឿង ម៉ាក IPHONE5 ពណ៌ស និងទូរស័ព្ទម៉ាក OPPO ពណ៌ខៀវ បានសម្រេចរួចរត់គេចខ្លួន ពិតប្រាកដមែន ។ មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកជនជាប់ចោទ ហេតុនេះ តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ **១៥៥៥ អ.ឃ.គ** ចុះថ្ងៃទី២៧ ខែ អេសា ឆ្នាំ២០២២ ទុកជាបានការដដែល និងសូមឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ណោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វិស្ស** បានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ, ក្រោយពីស្តាប់ការសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថាកូនក្តីរបស់ខ្លួនបានសារភាពទទួលស្គាល់ចំពោះសកម្មភាពរបស់ខ្លួនកន្លងមកដែលបានប្រព្រឹត្ត និងបានយល់ដឹងអំពីទោសកំហុសរបស់ខ្លួន ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង ព្រោះកូនក្តីរបស់ខ្លួនជាអនីតិជនមានការយល់ដឹងតិច និងខ្វះការពិចារណា ។

សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] **វិស្ស** បាននិយាយសំដីចុងក្រោយបង្អស់ថាបានសុំឱ្យតុលាការ ខ្លួនដឹងកំហុសហើយសំណូមពរឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំណូមពរសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិភាក្សា និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១១៨៥** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ មកជំនុំជម្រះ ដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ **២១៣៤** "ឡ" ដ.ដ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **វិស្ស** ភេទប្រុស **អាយុ១៧ឆ្នាំ** ជនជាតិខ្មែរ ទៅជំនុំជម្រះពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា**៣៥**៣ ,មាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**និយមន័យមាត្រា៣៥៣** និយមន័យនៃអំពើលួច គឺជាអំពើដកហូតដោយទុច្ចរិត នូវទ្រព្យសម្បត្តិ ឬ វត្ថុ ផ្សេងៗ ទៀត របស់អ្នកដ៏ទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-**និយមន័យមាត្រា៣៥៧** ទោសដែលត្រូវអនុវត្តអំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី)ឆ្នាំ ទៅ ១០ (ដប់)ឆ្នាំ ក្នុងករណី ១.អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រើហិង្សា ២.អំពើលួចនេះប្រព្រឹត្ត ដោយការកាប់គាស់ទម្លុះទម្លាយ។

-**និយមន័យមាត្រា៤៥** ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ក្នុងតារាងទី១ និងតារាងទី២ តាម គ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០,០០០ (មួយសែនរៀល) ទៅ ១,០០០ ,០០០៛ (មួយលាន រៀល) ។ ករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងអាចពិន័យជាប្រាក់ ពី ១ 000 000រៀល (មួយលានរៀល) ទៅ ២ 000 000រៀល (ពីរលានរៀល) ។

២-តាមដីកាសន្និដ្ឋានស្តាពរលេខ **១៥៥៥ អ.ឃ.ក** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ របស់អយ្យការអមសាលា ដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ថា កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ដែលជនជាប់ចោទឈ្មោះ [redacted] **វិស្នុ** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ប្រព្រឹត្តនៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ ២០២២ ប្រាកដមែន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វិស្នុ** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង០០និង៣០នាទី ឈ្មោះ ដេត ភេទប្រុស បានទូរស័ព្ទហៅបុរសម្នាក់មិនស្គាល់ឈ្មោះ ដើម្បីប្រើប្រាស់ គ្រឿងញៀនជុំគ្នានៅផ្ទះរបស់ឈ្មោះ គោ នៅចំណុចផ្លូវលំ ក្រុម៣៥ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ។ ពេលបុរសម្នាក់នោះមកដល់ពួកខ្លួនក៏នាំគ្នាចូលផ្ទះរបស់ឈ្មោះ គោ នាំគ្នាប្រើប្រាស់គ្រឿងញៀនជាមួយគ្នា ពេលនោះឈ្មោះ ដេត ក៏បានលួចប្រាប់ខ្លួនថាបុរសម្នាក់នោះ មានទូរស័ព្ទដៃម៉ាក IPHONE 11PROMAX ។ ពេលឮ ដូច្នេះខ្លួនក៏បានកាន់កាំបិតកែច្នៃ ដើរមកក្រៅផ្ទះរបស់ឈ្មោះ គោ រង់ចាំបុរសម្នាក់នោះចេញមកវិញ ដើម្បីត្រៀមប្លន់យក ទូរស័ព្ទពីបុរសម្នាក់នោះ ។ លុះម៉ោងប្រហែល០១និង០០នាទី បុរសម្នាក់នោះក៏បានដើរចេញមកខាងក្រៅ ហើយខ្លួនក៏ បានធ្វើសកម្មភាពភ្ជង់យកទូរស័ព្ទ០២គ្រឿង ម៉ាក IPHONE5 ពណ៌ស និងទូរស័ព្ទម៉ាកOPPO ពណ៌ខៀវ បានសម្រេចរួច រត់គេចខ្លួន ។ ហើយខ្លួនបានយកទូរស័ព្ទទៅឱ្យឈ្មោះ ម៉ុ ដើម្បីលក់នៅម្តុំផ្សារ៧មករា តែឈ្មោះ ម៉ុ បានគេចខ្លួនបាត់ទៅ ។ លុះនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២២ ខ្លួនក៏ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង ។ ពេលនេះខ្លួនដឹងបានហើយសូម តុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

តាមចម្លើយសារភាពរបស់ជនជាប់ចោទនាពេលសវនាការ តុលាការពិចារណាឃើញថា មានភាពស៊ីសង្វាក់ទៅ នឹងអង្គហេតុដែលបានកើតឡើង និងស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ជាពិសេសស៊ីសង្វាក់ទៅ នឹងភស្តុតាងនានាដែលមានក្នុងសំណុំរឿង អាចបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ ជន ជាប់ចោទ និងបក្ខពួកបានប្រើប្រាស់គ្រឿងញៀន និងបានយកកូនកាំបិតភ្ជង់ប្លន់យកទូរស័ព្ទដៃពីជនរងគ្រោះ ពិតប្រាកដ មែន ។ អំពើប្រព្រឹត្តនេះ គឺជាធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣,មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

Scanned with CamScanner

៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **វិស្សុ** ដែលបានប្រព្រឹត្តអំពើទុច្ចរិត លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នោះតុលាការពិចារណាឃើញថាជនជាប់ចោទរូបនេះពិតជាចាំដែលបានប្រព្រឹត្តអំពើល្មើសនេះដោយផ្ទាល់ប្រាកដមែន ហើយអំពើនេះបានបំពានទៅនឹងនីតិរដ្ឋនុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា៣៥៣, មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥-អំពើ និងសកម្មភាព របស់ជនជាប់ចោទធ្វើអោយខូចសណ្តាប់ធ្នាប់រៀបរៀបរយសាធារណៈ: ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស ។

៦-ជនជាប់ចោទ មានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ពេលប្រព្រឹត្តអំពើល្មើសច្បាប់រហូតបានសម្រេចតាមបំណងរបស់ខ្លួន ។

៧-ជនជាប់ចោទឈ្មោះ [redacted] **វិស្សុ** ភេទប្រុស អាយុ**១៧**ឆ្នាំ ជាអនីតិជន តាមមាត្រា ១៦០ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ) នៃក្រមព្រហ្មទណ្ឌបានចែងថា "កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅមូលទោសលើបទល្មើស ដែលចោទប្រកាន់ត្រូវបានបន្តយក្នុងលក្ខខណ្ឌដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្តយពាក់កណ្តាលហេតុដូច្នេះ គប្បីតុលាការពិចារណាតាមច្បាប់ ។

៨-តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ: **១៥៥៥ អ.ឃ.គ** ចុះថ្ងៃទី**២៧** ខែមេសា ឆ្នាំ**២០២២** ទុកជាបានការដដែល និងសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ចំណុចនេះគប្បីតុលាការពិចារណា និងសម្រេចតាមការប្តឹងសុំនេះ ។

៩-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វិស្សុ** បានធ្វើសេចក្តីសន្និដ្ឋានការពារថាក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ, ក្រោយពីស្តាប់ការសន្និដ្ឋានរបស់តំណាងអយ្យការឃើញថា កូនក្តីរបស់ខ្លួនបានទទួលស្គាល់ចំពោះសកម្មភាពរបស់ខ្លួន និងបានយល់ដឹងអំពីទោសកំហុសរបស់ខ្លួនដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសុំឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្លួនផង ។ ចំណុចនេះគប្បីតុលាការលើកយកមកធ្វើការពិចារណាលើការស្នើសុំរបស់លោកមេធាវី ។

១០-ជនជាប់ចោទឈ្មោះ [redacted] **វិស្សុ** បានសំណូមពរសំដីចុងក្រោយថា សុំឱ្យតុលាការជួយបន្ធូរបន្ថយទោស ដល់រូបខ្លួនផង ព្រោះបានដឹងពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តនេះហើយ ។ គប្បីតុលាការពិចារណាលើការស្នើសុំរបស់ ជនជាប់ចោទ។

១១-វត្ថុចាប់យកដែលត្រូវរឹបអូសរួមមាន៖ កាំបិតកែឆ្នៃចំនួន**០១** ដើមប្រវែង ៥០សង់ទីម៉ែត្រ មានដងជ័រ ពណ៌ខ្មៅ ។ វត្ថុចាប់យកនេះមានទំនាក់ទំនង និងបំរើឱ្យសកម្មភាពប្រព្រឹត្តបទល្មើសកើតមានឡើង ហេតុដូច្នេះគប្បីតុលាការសម្រេចរឹបអូស ។

១២-មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **វិស្សុ** ភេទប្រុស អាយុ**១៧**ឆ្នាំ ជនជាតិខ្មែរ ពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ក្រុមពា៥ ភូមិពា សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី**០៧** ខែមីនា ឆ្នាំ**២០២២** តាមបញ្ញត្តិមាត្រា**៣៥៣** ,មាត្រា**៣៥៧** នៃក្រមព្រហ្មទណ្ឌ និងអាត្រា**៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

Scanned with CamScanner

ហេតុផ្តេចផ្តើមសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ទិស្ស** ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **១៨ខែ** (**ដប់ប្រាំបីខែ**) ពីបទ **លួចមានស្ថានទម្ងន់ទោស និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលំ ក្រុមពា៥ ភូមិពា សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា**៣៥៣** ,អាត្រា**៣៥៧** ,អាត្រា**១៦០** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-**វត្ថុចាប់អកដែលត្រូវរឹបអូសរួមមាន**៖ កាប៊ូតកែឆ្នៃចំនួន០១ដើមប្រវែង៥០សង់ទីម៉ែត្រមានដងជ័រពណ៌ខ្មៅ ។

សាលក្រមនេះជំនុំជម្រះជារសាធារណៈនាថ្ងៃទី០៣ ខែសីរក ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វិស្ស** ,**ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ** និងប្រកាសជារសាធារណៈនៅថ្ងៃទី១១ ខែសីរក ឆ្នាំ២០២២។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និង ត្រា	ហត្ថលេខា	ហត្ថលេខា	ហត្ថលេខា និង ត្រា
[redacted]			

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

Scanned with CamScanner